


**<u>ការបើកឲ្យដាក់ពាក្យចូលរួមកម្មវិធី KAS – For Legal Youth 2022</u>**

ដើម្បីគាំទ្រដល់យុវជន ក្នុងវិស័យច្បាប់នៃប្រទេសកម្ពុជា Konrad-Adenauer-Stiftung (KAS) Cambodia បានបង្កើតកម្មវិធី KAS-For Legal Youth (KAS-FLY) ក្នុងគោលបំណងលើកកម្ពស់ និងគាំទ្រដល់ការអភិវឌ្ឍជំនាញវិជ្ជាជីវៈ និងជំនាញផ្ទាល់ខ្លួនរបស់និស្សិតច្បាប់ និងអ្នកវិជ្ជាជីវៈវ័យក្មេងដែលធ្វើការក្នុងវិស័យច្បាប់នៅកម្ពុជា ។ ចាប់តាំងពីឆ្នាំ 2017 មក កម្មវិធីនេះបានផ្សារភ្ជាប់ទំនាក់ទំនងរវាង យុវជនក្នុងវិស័យច្បាប់ជាមួយនឹងអ្នកជំនាញផ្នែកច្បាប់ ទាំងក្នុងស្រុក និងអន្តរជាតិ ។ ជារៀងរាល់ឆ្នាំ បេក្ខជន 15 ទៅ 20 នាក់ត្រូវបានជ្រើសរើសឱ្យចូលរួមក្នុងកម្មវិធី KAS-FLY ហើយអនុវត្តតាមរបៀបវារៈនៃកម្មវិធីចាប់ផ្តើមពីខែកុម្ភៈ ដល់ខែវិច្ឆិកា ឆ្នាំ 2022 ដែលរួមមានប៉ុន្តែមិនកំណត់ចំពោះ ៖

- ការទទួលស្វាគមន៍ និងការជួបជុំអតីតសមាជិក KAS-For Legal Youth
- សិក្ខាសាលា និងពិភាក្សាខ្លឹមសារច្បាប់
- ទស្សនកិច្ចសិក្សាទៅកាន់ស្ថាប័នច្បាប់ ឬនយោបាយក្នុងប្រទេសកម្ពុជា
- ការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ និងជំនាញទន់
- សន្និសីទច្បាប់ (កិច្ចពិភាក្សាច្បាប់លើកទី ២១ ដែលរៀបចំដោយ KAS Cambodia)
- ដំណើរកម្សាន្តជាក្រុមនៅពេលបញ្ចប់កម្មវិធី

កម្មវិធីចាប់បើកទទួលពាក្យពីថ្ងៃទី២១ ខែមករា រហូតដល់ ថ្ងៃទី១៤ កុម្ភៈ ឆ្នាំ២០២២ សម្រាប់និស្សិតច្បាប់ទាំងអស់ និងអ្នកដែលទើបតែចាប់ផ្តើមធ្វើការក្នុងវិស័យច្បាប់នៅប្រទេសកម្ពុជា ។ បេក្ខជនដែលមានចំណាប់អារម្មណ៍ សូមផ្ញើប្រវត្តិរូបសង្ខេប (CV) និងសំណេររៀបរាប់ពីចំណាប់អារម្មណ៍ក្នុងការចូលរួមមកកាន់ អ៊ីម៉ែល chanbormey.long@kas.de យ៉ាងយូរត្រឹមថ្ងៃទី **១៤ ខែកុម្ភៈ ឆ្នាំ ២០២២ ម៉ោង ៥ រសៀល**។

**លក្ខណៈវិនិច្ឆ័យសិទ្ធិក្នុងការដាក់ពាក្យ៖**

អ្នកដាក់ពាក្យត្រូវតែ៖

• អាយុក្រោម 28 ឆ្នាំ និង

• ជាសិស្សឆ្នាំទី៣ ឬទី៤ ក្នុងមុខជំនាញច្បាប់ ឬ

• ជាអ្នកកាន់សញ្ញាបត្រអនុបណ្ឌិតផ្នែកច្បាប់ ឬ

•ជាអ្នក វិជ្ជាជីវៈវ័យក្មេងដែលធ្វើការក្នុងវិស័យច្បាប់នៅកម្ពុជា

**អត្ថប្រយោជន៍ក្នុងការចូលរួម៖**

• ក្លាយជាផ្នែកមួយនៃបណ្តាញសម្បូរបែប និងចម្រុះរបស់ KAS នៅក្នុងវិស័យច្បាប់។

• ឱកាសដើម្បីចូលរួមការបណ្តុះបណ្តាល/ការពិភាក្សាផ្នែកច្បាប់ និងការបណ្តុះបណ្តាលជំនាញទន់ដែលផ្តល់ដោយអ្នកជំនាញរបស់ KAS

• ឱកាសចូលរួមទស្សនកិច្ចសិក្សានៅស្ថាប័នច្បាប់/នយោបាយ នៅកម្ពុជា

• ឱកាសក្នុងការស្នើសុំ និងអនុវត្តគម្រោងផ្ទាល់ខ្លួនរបស់អ្នកនៅក្នុងក្រុមដោយមានការគាំទ្រពី KAS

**របៀបដាក់ពាក្យ៖**

បេក្ខជនដែលមានចំណាប់អារម្មណ៍ ក្នុងការដាក់ពាក្យ តម្រូវឲ្យផ្ញើប្រវត្តិរូបសង្ខេប (CV) និងសំណេររៀបរាប់ពីចំណាប់អារម្មណ៍ក្នុងការចូលរួម (Motivation Letter) មកកាន់ អ៊ីម៉ែល chanbormey.long@kas.de  យ៉ាងយូរត្រឹមថ្ងៃទី **១៤ ខែកុម្ភៈ ឆ្នាំ ២០២២ ម៉ោង ៥ រសៀល** ។ ឯកសារដែលត្រូវផ្ញើទាំងអស់ត្រូវតែបញ្ចូលទៅក្នុងទម្រង់ PDF តែមួយ (យ៉ាងច្រើន ៣ ទំព័រ)។

បេក្ខជនដែលជោគជ័យនឹងត្រូវបានទាក់ទងសម្រាប់ព័ត៌មានបន្ថែមអំពីការសម្ភាសន៍ និងកម្មវិធី។

***ចំណាំសំខាន់៖**

សំណេររៀបរាប់ពីចំណាប់អារម្មណ៍ក្នុងការចូលរួម (Motivation Letter) របស់អ្នកត្រូវតែឆ្លើយសំណួរខាងក្រោម៖

1. ហេតុអ្វីបានជាអ្នកជ្រើសរើសច្បាប់ជាមុខជំនាញសិក្សា/ការងាររបស់អ្នក?

2. ហេតុអ្វីបានជាអ្នកចង់ដាក់ពាក្យ KAS-FLY 2022?

3. តើកម្មវិធីនឹងជួយអ្នកយ៉ាងដូចម្តេច?

***ព័ត៌មានបន្ថែម៖**

ស្វែងរកព័ត៌មានជាភាសាអង់គ្លេសនៅលើគេហទំព័រ https://www.kas.de/en/web/kambodscha/veranstaltungen/detail/-/content/kas-for-legal-youth-network

សម្រាប់សំណួរទាក់ទងនឹងកម្មវិធី ឬការដាក់ពាក្យ សូមអ៊ីម៉ែលទៅកាន់ chanbormey.long@kas.de ឬ ទាក់ទងទៅទូរសព្ទ ០៨៧ ៨៨០ ៩៩៥ ។